ញ៉ុក . ង៉ែម

# មហាវេស្សន្តរជាតក



គណ្ឌទី ១១

ផ្សាយទេញភិ “[illegible]”

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## ទី ១១

## កណ្ឌមហារាជបព្វ

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តទា ពោធិសត្តោ ច មទ្ទី ច សម្មោទមានា សត្ត-ទត្តិយេ អស្សមេ វសឹសុ ។

ពោធិសត្តោ ច រីព្រះបរមពោធិវង្ស ទ្រង់ព្រតទាំងពីរព្រះអង្គ គឺសម្ដេចព្រះបរមពោធិវង្ស គ្រងពិភពធានី មទ្ទី ច នូវសម្ដេចព្រះមទ្រីដ៏ជាអគ្គមហេសី ស្រីគ្រប់លក្ខណា ដ៏ជាត្រកូលខិត្តិយវង្ស សម្មោទមានា ក្សត្រទាំងពីរព្រះអង្គ ទ្រង់មានព្រះទ័យស្មោះសរដោយនូវព្រះពរទាំង ៨ ប្រការ វសឹសុ ឥតវង្វៀសក្នុងព្រះរាជហឫទ័យ ពុំមានភយន្តរាយ អស្សមេ ក្សេមក្សាន្តសប្បាយនៅនាព្រះអាស្រម សត្តទត្តិយេ ដែលព្រះឥន្ទ្រាធិរាជរឹងឫទ្ធិ ព្រះអង្គព្រះរាជទានឱ្យមកនោះឯងហោង ។

ជជ្ជកោបិ កុមារេ គហេត្វា សដ្ឋីយោជនមគ្គំ បដិបជ្ជិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ កាលនោះ តាជូជកព្រាហ្មណ៍បានចៅជាលី និងនាងក្រស្នាហើយ ក៏រលះរលាំងបណ្ដើរទៅ ដោយនូវផ្លូវចម្ងាយ ៦០ យោជន៍នោះ ។ ទេវតា កុមារពំអារក្ខមកាំសុ ក្បិណនោះកូវ អស់ទេវតាទាំងឡាយជួយថែរក្សាកុមារទាំងពីរ ដែលតាជូជកនាំបណ្ដើរទៅ មិនឱ្យមានជម្ងឺឈឺថ្កាត់តាមផ្លូវឡើយ ។

ជូជកកោបិ សុរិយេ អដ្ឋង្គមិតេ កុមារេ គច្ឆេ ពន្ធិត្វា កាលព្រះសុរិយាទន់ទាបល្ងាច ថ្ងៃបាំងនឹងជ្រុងភ្នំព្រះសិនេរុរាជគិរិន្ទរយប់ព្រលប់សន្ធិយា ឮតែសូរសព្ទសំឡេងមៀម ទីទុយច្រឡំ នូវសំឡេងលលកខ្មោចយំកងរំពងទាំងព្រៃ ។ ឯតាជូជកអប្រិយ ក៏ភ័យខ្លាចពន់ប្រមាណ ទើបគាត់ខំវាយព្រះរាជកុមារបណ្ដើរទៅ ឥតបង្អង់សម្រាកឡើយ ។ ឱះឱ! មុខគួរអាសូរចៅជាលី និងនាងក្រស្នា អ្នកទ្រង់ព្រះសោកាពន់ប្រមាណ ទើបមានអស់ពួកទេវតាផ្អៀងព្រះកាណ៌ស្ដាប់ឮសព្ទសូរសៀង សំឡេងជាលីនិងនាងក្រស្នា អ្នកមានព្រះទ័យអនាថអាណិត ពុំដឹងបើនឹងគិតដូចម្ដេចឡើយ ។ ឱទ្រូងអញអើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្មើរនឹងបែកសញ្ញែកប្រេះចេញ ព្រោះត្បិតព្រះរាជបុត្រទាំងគូមិញ អ្នកដើរជជ្រុលជជ្រកខំប្រវារកគ្នា ឯព្រាហ្មណ៍ចាស់ជរាក៏ភិតភ័យខ្លាចក្រែងព្យគ្ឃៈ សិង្ហសីហ៍ ធ្វើឱ្យអន្តរាយជីវិត ទើបគាត់ចូលទៅក្នុងព្រឹក្សា ហើយបោចយកលតាវល្លិផងចងព្រះកុមារទាំងពីរ គួបរួបរឹតជិតជាប់ផងគ្នា ផ្ដេកនៅនាគល់ឈើ ហើយពុំលង់ឡើយ ភ្នែកគាត់រំពៃជើងដៃសឹងពានឡើងកកេបកកាប ផ្ទាសនឹងដល់ទៅប្រគាបឈើនៅលើចុងព្រឹក្សា គាត់ចងព្រះរាជកុមារទាំងពីរទុកនៅដី ឯព្រាហ្មណ៍ចាស់អប្រិយនឿយណាស់ ប្រះដេកលក់ស្រមុកទៅ *សាខវិដបស្សព្ភន្តរេ* នៅនាប្រគាបឈើនោះឯងហោង ។

*តស្មឹ ខណេ* ឰដ៏កាលនោះមុខគួរឱ្យស្រណោះ ចៅជាលីនិងនាងក្រស្នាទាំងពីរ ព្រាត់ប្រាសព្រះមាតា អ្នកទួញសោករកព្រះជននី *ឯកោ ទេវបុត្តោ* មានទេវបុត្រមួយអង្គ ទ្រង់នូវចេស្ដានុភាពកបនូវព្រះទ័យករុណា ប្លែងកាយាចុកចងព្រះកេសា ទ្រង់នូវកុណ្ឌលហ្វរ៉ែកពាក់ស្បែកខ្លាជាសង្វារ សម្បុរច្រាលវិលវង់ ទ្រង់សឹងគ្រឿងទិព្វដ៏មានតម្លៃ ព្រះភក្ត្រប៉ប្រែប៉ប្រិម ព្រះឱស្ឋញញឹមរួសរាយ ស្មោះសរល្អសុទ្ធ

Websites: WatKhemaraRatanaram.org or WatKhmers.org

សាធ ដូចកលនៃព្រះបាទស្រីវេស្សន្តរ ឯកា ទេវតា មាននាងទេព អប្សរបវរកញ្ញា នៅនារុក្ខាឋាននោះ មានចិត្តករុណា ទើបនិម្មិតកាយា ឱ្យសមជាស្រីឧត្តមប្រសើរ ដើរញៀងញ៉ងតាមទំនងចរិតក្សត្រី ដូចកល សម្តេចព្រះនាងមទ្រី មានលក្ខណាចងជដាជាភេទតសី ដូចព្រះជននី នូវព្រះជនក ស្តេចយាត្រាមកស្វែងរក មោចេត្វា ទើបស្រាយចំណង ចេញអំពីព្រះហស្ត នៃព្រះរាជកុមារទាំងពីរស្រេច ស្តេចគក់ព្រះឱរា ទ្រង់ព្រះសោកាពិលាបថា ឱ ! អម្ចាស់ម្តាយអើយ ម្តេចឡើយក៏ មកបានសេចក្តីលំបាកពីតូច ៗ ឱះឱ ! ព្រះកាយអ្នកដូចគេសាប់សព្វ សព៌ាង្គ សឹងតែស្នាមឈាមហូរដូចគេស្រពស្រោចកាយា ទ្រូងព្រះ មាតានេះ ស្ទើរនឹងបែកសព្វែកប្រេះចេញ នាកាលគ្រានេះមិញ ហត្ថ- ចាទេ សម្ពាហិត្វា ឱកូនសម្លាញ់ម្តាយអើយ ចូរមក ឯមាតាបិតានឹង បានពិភ័ក្តិរក្សាអស់ជម្ងឺក្នុងប្រាណឱ្យបានសះស្បើយ ។ ពុំលង់ឡើយ ទេព្តាក៏ល្ងងលោមបីថ្នមព្រះរាជកុមារនៃបនិត្យជិតព្រះឱរា ហើយ ត្រាស់ថា មេក្រស្នាសម្លាញ់ម្តាយអើយ ចូរអ្នកមកបៅបន្តិចសោះឃ្លាន ម្តាយនេះពុំមានដំណឹងថា អ្នកលំបាកដល់ម្ល៉េះឡើយ ឥហាបេត្វា

Websites: WatKhemaraRatanaram.org or WatKhmers.org

ទើបនាងទេពធីតា យកទឹកមកលុបព្រះភក្រ្ត ជុះព្រះអង្គ ចងជដាផ្ចិតផ្ចង់ ឱ្យមានមង្គលសួស្តី ភុញ្ជាបេត្វា ទើបត្រាស់ថា កូនសម្លាញ់ម្តាយអើយ អ្នកអត់អាហារល្ហិតល្ហៃ នៅក្នុងព្រៃព្រឹក្សា ឯអស់ភោជនាហារ ក៏ម្តាយយកមកផ្ញើកូនគូកំសត់ ។ ទើបទេវបុត្រ និងនាងទេពធីតា លួងលោមថៅចាលីនិងនាងក្រស្នា ឱ្យសោយគ្រឿងទិព្វសម្រេចហើយ ទើបលើកព្រះហត្ថាអង្អែល បីផ្ទមលួងលោម ឱ្យផ្ទំនៅលើពូកព្រំខ្នល់ខ្នើយទិព្វជាបរមសុខ ។ អ្នកផ្ទំលក់ស្កល់ លុះដល់អរុ-ណោទ័យបែករស្មីបំព្រាង ស្វាងជ្រះស្រឡះមេឃ ទេព្តារក្សាព្រះរាជកុមារទាំងពីរ បណ្តាលឱ្យគង់ចំណងដូចដែលវិញ ក្រែងព្រាហ្មណ៍នោះមិញ វានឹងខឹងឃោរឃៅ ជេរពោលវាយដំពុំប្រណី ។

ឯវត្ថេ ទេវតាសង្គហេន ក៏ហេតុទេព្តារក្សាព្រះកុមារទាំងគូដោយនូវផ្លូវត្រូវជា ១៥ រាត្រី អរោគា ហុត្វា ពុំមានភ័យរោគាព្យាធិដោយតេជៈបារមីនៃទេព្តា នូវបុណ្យព្រះរាជកុមារាកុមារី នូវបរមត្ថបារមី នៃព្រះរាជឥសីដ៏ជាព្រះវររាជបិតា កាត់តម្លាសទ្វានោះឯង អរុ-ណោ នាកាលអរុណោទ័យរស្មីភ្លឺជ្រះស្រឡះមេឃ ក្បែណនោះ ជូជក

ចាស់ជរាភ្ញាក់ពព្រើត ទើបបានងើបក្បាលឡើងដឹងជាភ្លឺ គាត់ថាហឺះ ៗ អេះព្រឹកភ្លឺហើយហ្ន៎ ! ទើបគាត់ក្រោកពីនិទ្រាកខ្វេសកខ្វាសពពីបពពាប យកទឹកមកលុបមុខខ្ពុរមាត់ គាត់បរិភោគសង្ខវខៅតាក ឆ្អែតស្រេចហើយ ពុំលង់ឡើយគាត់ក៏ចុះពីប្រគាបឈើ មោចេត្វា ទើបគាត់ស្រាយលតាវល្អិផង ដែលចងព្រះហស្តព្រះរាជកុមារទាំងគូ បណ្តើរនាំទៅដោយនូវផ្លូវ គិតថានឹងដើរស្រូតទៅឱ្យរំលងទ្វារព្រៃនោះ ជិស្វា លុះដល់មាគ៌ាបែកជាពីរ ផ្លូវមួយនោះនឹងទៅឯក្រុងពិជ័យជេតុត្តរនគរ ឯផ្លូវមួយទៀតនោះនឹងទៅនគរកលិង្គរាស្ត្រ ដ៏ជាឋាននៃអាត្មា ទើបទេព្តាបញ្ចូលចិត្ត ឱ្យគាត់ងឿងឆ្ងល់សង្ស័យស្មានថាផ្លូវដែលទៅជេតុត្តរនគរ គិតថាជាផ្លូវនឹងទៅកលិង្គរាស្ត្រវិញជាប្រាកដ ។ ទើបគាត់នាំព្រះរាជបុត្រទាំងពីរទៅដោយនូវមាគ៌ា អឌ្ឍមាសា ថាបើគណនាបាន ១៥ ថ្ងៃ ទើបបានដល់ក្រុងពិជ័យជេតុត្តរនគរនោះឯងហោង ។

តំ ជិវសំ បច្ចូសកាលេ លុះព្រឹកឡើងថ្ងៃ ១៥ កើតជាថ្ងៃឧបោសថ រាជា សញ្ជយោ ឯព្រះបាទក្រុងសញ្ជ័យដ៏ទ្រង់ឫទ្ធិនាកាលព្រះបរមបពិត្រ ស្តេចនឹងបានយល់ព្រះរាជនត្តានត្តាទាំងពីរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គ ទ្រង់ព្រះសុបិននិមិត្តជាអស្ចារ្យ ហាក់ដូចព្រះអង្គគង់នៅនាក្រឡាព្រះគំនាល់កណ្ដាលផ្ទៃរោង ថ្កើងដោយនូវព្រះបារមីចេស្ដា មានអស់សេនាមាត្យគង់គាល់ ដោយនូវរបៀបត្រៀបត្រា ជំនុំពិចារណារាជការផ្ទៃក្រោម ។ ឯកោ បុរិសោ មានបុរសម្នាក់ គណ្ហោ រូបរាងខ្មៅស្រមាកធាត់ធំមហិមា ទ្វេ បទុមានិ អាហរិត្វា មានដៃកាន់នូវបទុមាផ្កាឈូកទាំងពីរ ទ្រង់ទតរមិលមើលយល់ផ្កាមួយនោះក្រពុំ ឯបទុមមួយនោះ រំសាយកេសរពិដោររល្វេងល្វើយ រញ្ញោ ហត្ថេ ឋបេសិ បុរសនោះឯង យកមកថ្វាយដាក់បូជានៅនាព្រះហស្ត បិលន្ធតិ ក្នុងព្រះសុបិននោះថា ព្រះអង្គទទួលយកមកសៀតនៅនាព្រះកាណ៌ទាំងសងខាងល្អប្រសើរ វេណ្ហូ ភស្សិត្វា រីឯលំអងកេសរក៏ជ្រុះលើព្រះឧរា កេសរផ្កាមានក្លិនក្រអូបពុំស្បើយ ចាគោរ លុះព្រឹកឡើងហើយ ស្ដេចត្រាស់ឱ្យហៅហោរាព្រឹទ្ធាចារ្យមកដល់ស្រេច ទើបស្ដេចមានព្រះរាជឱង្ការប្រាប់ហោរាព្រឹទ្ធាចារ្យតាមដោយនូវបុព្វនិមិត្ត ។ ទើបពួកហោរាក្រាបថ្វាយបង្គំទូលថា បពិត្រព្រះរាជសម្ភារ រីនិមិត្តនេះត្រកាលល្អណាស់អម្ចាស់ ចិរប្បវុឌ្ឍា ព្រះរាជវង្សាអម្ចាស់ ដែលព្រាត់ចាកចេញទៅឆ្ងាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាអម្លុងឃ្លូវ ឥឡូវនេះនឹងវិលមកពឹងព្រះបរមពោធិសម្ភារព្រះអង្គ ជាប្រាកដពុំខានឡើយ ។ ទើបស្តេចមានព្រះរាជហឫទ័យត្រេកអរពន់ប្រមាណ យល់បានដូចព្រះបំណង ទើបស្តេចចូលទៅកក់ស្រង់ទ្រង់ព្រះសុគន្ធពិដោរឈ្ងុយឈ្ងប់សព្វព្រះកាយ ឆ្លុះព្រះឆាយ សិតព្រះកេសា ហើយស្តេចសោយព្រះក្រយាស្ងោយ ដ៏មានឱជារសរួចស្រេចស្តេចលីលាចេញទៅគង់នៅនាព្រះគំនាល់ អស់សេនាមាត្យគាល់ត្រៀបត្រា ។ ស្តេចទ្រង់ព្រះចិន្តាពិចារណាអំពីរាជការ ផ្ទៃក្រោមនោះឯងហោង ។

ឮដ៏កាលនោះ ទេវតាបញ្ចូលចិត្តឱ្យជូជកព្រាហ្មណ៍ ដឹកនាំព្រះរាជកុមារទាំងពីរព្រះអង្គ ទៅត្រង់មុខព្រះលាន ។ អស់មនុស្សផងទាំងឡាយ ក៏ពុំបានសាកសួរសេចក្តីនៃតាចាស់ជរា ជាមនុស្សអប្រិយ គាត់នាំព្រះរាជបុត្រាបុត្រីទៅជិតព្រះរាជវាំង ក៏ព្រោះទេវតាបំបាំងក្នុងចិត្តឱ្យភ្លេចភ្លាំងទាំងស្រីទាំងប្រុសគ្រប់គ្នា ឱ្យជាពុំបានសាកសួរឱ្យដឹងដំណើរ ។ ឯព្រាហ្មណ៍ក៏បណ្តើរព្រះរាជកុមារទាំងគូ ចូលទៅដល់មុខព្រះលាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

រាជា សញ្ជយោ ទើបសម្តេចព្រះបរមក្សត្រក្រុងស្រីសញ្ជ័យ ស្តេចទតព្រះនេត្រទៅយល់ព្រះរាជនត្តានត្តាទាំងគូ ស្តេចពុំស្គាល់ ទើបត្រាស់ជាអាថ៌បាទព្រះគាថាដូច្នេះ ៖

កាស្សេតំ មុខមាភាតិ ហេមំ វុត្តុត្តមគ្គិជា
និក្ខំវ ជាតរូបស្ស ឧក្កាមុខបហំសិតំ ។
ឧភោ សទិសបច្ចង្គា ឧភោ សទិសលក្ខណា
ជាលិស្ស សទិសោ ឯកោ ឯកា កណ្ហាជិនា យថា ។
សីហា វិលាវ និក្ខន្តា ឧភោ សម្បត្តិរូបកា
ជាតរូបមយាយេវ ឥមេ ទិស្សន្តិ ទារកាតិ ។

ភោ អមច្ចា ហែអស់សេនាមាត្យផងទាំងឡាយអើយ រីព្រាហ្មណ៍បណ្តើរក្មេងទាំងពីរនោះ តើជាបុត្រនៃអ្នកឯណាហ្ន៎ះ មើលទៅយល់ថ្លៃថ្លាប្រសើរបវរសុទ្ធស្អាត ហេមមិវ ដូចសុវណ្ណជាតិជម្ពូនុទ វុត្តុត្តមគ្គិជា គិតដ៏ត្រូវរន្ទះថ្ងៃ ដ៏មាននូវរស្មីនោះពព្រាលពព្រាយ និក្ខំវ ជាតរូបស្ស ពុំនោះសោត ព្រះភក្ត្របីដូចកលមាសនព្វគុណ បហំសិតំ

គិតដ៏នាយជាងទងរំលាយនៅក្នុងមាត់ផ្គរ [1] ដ៏មានទឹកនោះ រលើបរលង់ត្រចង់ត្រចះជ្រះថ្លាឥតរាគី ឧភោ សជិសបច្ចង្គា ព្រះរាជកុមារកុមារីទាំងពីរអ្នក ទ្រង់នូវព្រះឆោមបវរព្រះករទន់ភ្លន់ បើនឹងគន់ទៅ ក៏យល់ល្អប្រសើរស្រស់ស្រួលមុខគួរឱ្យអាសូរករុណា អ្នកបណ្ដើរគ្នាមកទាំងគូ ឧភោ សជិសលក្ខណា ទ្រង់នូវលក្ខណាល្អដូចគ្នា ហាក់ដូចពុម្ពមួយ ពុំមានឃ្លាតឃ្លៀង ល្អៀងដល់តិចឡើយ ឯកោ ឯកាឯកុមារាហាក់ដូចជាបាជាលីថៅសម្លាញ់ មួយតូចនោះមិញដូចនាងក្រស្នា ត្រូវដូចពាក្យហោរាទំនាយ មានរូបឆោមឆាយឥរិយាលំនាំសមសារ សមជាកូនត្រកូលក្សត្រ ទើបពុំគិតក្រែងខ្លាចអាចដើរមកដល់នេះ សីហា វិលោវ និក្ខន្តា យាត្រាបីដូចកលកេសររាជសីហ៍ ដ៏មានឫទ្ធិមហិមាចេញពីគុហាកែវប្រសើរ ដ៏មានដំណើរល្អដូច្នោះ ឧភោ សម្បត្តិរូបកា អស់អង្គកាយានោះ ក៏មានពណ៌សម្បុរល្អ យល់ឆើតឆាយ ជាតរូបមយាយេវ ឥមេ និស្សន្តិ ទារកា បីដូចជាសុវណ្ណដ៏មាន

[1] - មាត់បាវ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

វស្មី អញនឹងបានយល់រាជកុមារាកុមារី អ្នកឃាត្រាមកដល់ជាប្រាកដឥឡូវនេះឯង ។

បពិត្រអើយ ឰដ៏កាលនោះ ព្រះបាទក្រុងស្រីសញ្ជ័យនរិន្ទរាជាឥស្វរចមក្សត្រ ព្រះអង្គសរសើរព្រះរាជនត្តានត្តា ដោយនូវបាទព្រះគាថាបីបទស្រេចហើយ ពុំយូរឡើយ ត្រាស់ប្រើអាមាត្យមួយចេញទៅយកជូជកព្រាហ្មណ៍ចាស់ជរាអ្នកអន្ធការ ហើយយកព្រះរាជកុមារទាំងពីរ ចូលមកថ្វាយព្រះអង្គជាប្រញាប់ ។ ក្សិណនោះ អាមាត្យស្តាប់ព្រះរាជឱង្ការហើយ ពុំលង់ឡើយ ក៏រត់ចេញទៅចាប់យកព្រាហ្មណ៍ នូវព្រះរាជកុមារមកថ្វាយ ដោយនូវព្រះបរមរាជឱង្ការ ។ ឯព្រះបាទក្រុងស្រីសញ្ជ័យ កាលណាបើព្រាហ្មណ៍ចាស់ជរាមកដល់ហើយ ព្រះអង្គពុំឱ្យអាមាត្យរាជសេនាដណ្តឹងឡើយ ព្រះអង្គត្រាស់ដណ្តឹងផ្ទាល់នឹងព្រះឱស្ឋព្រះអង្គឯង ឱ្យប្រាកដសូត្រជាបាទព្រះគាថាដូច្នេះ ៖

កុតោ នុ ត្វំ ភារទ្វាជ ឥមេ អានេសិ ទារកេ

អជ្ជ រដ្ឋមនុប្បត្តោ កុតោ អាគច្ឆសិ ព្រាហ្មណាតិ

អើព្រាហ្មណ៍អើយ អញចង់ដណ្តឹងព្រះស្តែង ព្រាហ្មណ៍ឯង

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាពូជពង្សអ្នកស្នមទាន ចូរព្រះស្តែងប្រាប់អញឱ្យបានដឹងតែដោយនូវពិតកុំមុសា ឥមេ អាគេសិ ជាលកោ រីឯកុមារីកុមារានេះ តើព្រាហ្មណ៍បានមកពីឋានឯណាហ្ន៎ះ? អជ្ជ រដ្ឋមនុប្បត្តោ នាំមកប៉ុន្មានថ្ងៃហើយទើបបានដល់ពិជ័យជេតុត្តរបវររាជធានីណាព្រាហ្មណ៍ ចូរព្រះស្តែងប្រាប់អញតាមពិត ។

មយ្ហន្តេ ជាលកោ ទេវ ជិន្នា ចិត្តេន សញ្ជយ
អជ្ជ បណ្ណរសា រត្តិ យតោ លទ្ធា មេ ជាលកាតិ ។

ជូជកោ អាហ ជូជកព្រាហ្មណ៍ក៏ភិតភ័យខ្លាច ពុំអាចនៅស្ងៀមបានឡើយ ហើយក្រាបទូលស្នងព្រះរាជឱង្ការថា សញ្ជយបពិត្រព្រះភូមិន្ទនរិន្ទនរនាថ ព្រះបាទនារាយណ៍នរបតីស្រីសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអម្ចាស់ខ្ញុំអើយ រីឯព្រះរាជកុមារទាំងពីរនេះគឺព្រះបាទស្រីវេស្សន្តរ ព្រះអង្គទ្រង់កាត់តម្លាសទ្វាឱ្យទានមកខ្ញុំតាជីចិត្តេន ត្បិតព្រះអង្គមានព្រះរាជហឫទ័យ ត្រអាលសោមនស្សានឹងជូរយកព្រះប្រាជ្ញាសព្វេញ្ញូតាញាណ យតោ លទ្ធា នាកាលទទួលព្រះរាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាន ខាងឯខ្មើតបណ្ណរសី ខ្ញុំតាជីនាំមក បណ្ណរសធិវសា បាន ១៥ ថ្ងៃហើយអម្ចាស់ ។

កោន វាចាយ បេយ្យេន　　　សម្មា ញាយេន សទ្ធហេ
កោ តេ តំ ធានមទ្ទធា　　　បុត្តកោ　ធានមុត្តមន្តិ ។

រាជា អាហ ទើបមហាក្សត្រត្រាស់ថា អើតាជីអើយ ចូរឆ្លើយវិញទៀតមើល ត្បិតអញយល់ពុំសម ធម្មតាប្រពៃណីសត្វក្នុងវដ្ដសង្សារទាំងឡាយនៅនាលោកិយ ឯបុត្រាបុត្រីទុកស្មើនឹងជីវិត ដូចម្ដេចក៏គិតកាត់ឱ្យជាទានដូច្នេះបាន ? កោន វាចាយ បេយ្យេន ឬមួយព្រាហ្មណ៍ល្ងងលោមដោយនូវវាចាឯណា ព្រះទ័យព្រះអង្គកាត់តម្លាសទ្ធាស្រាប់ពិតមែន តែម្ដេចក៏យកបុត្រឱ្យជាទាន យល់ជាពុំដែលមាន ប្លែកក្រៅវិស័យជាអស្ចារ្យ បើដូច្នោះ តើព្រះស្ដែងនឹងយកអ្វីមកជាបន្ទាល់សាក្សី សទ្ធហេ ឱ្យអស់មន្ត្រីគេជឿជាក់ប្រាកដផងមើលណាព្រាហ្មណ៍ ?។

យោ យាចតំ បិតដ្ឋាសិ　　　ភូតានំ ធរណីរិវ
សោ មេ វេស្សន្តរោ រាជា　　　បុត្តេធាសិ វនេ វសំ ។

Websites: WatKhemaraRatanaram.org  or  WatKhmers.org

យោ យាចតំ គតិ អាសិ      សវន្តីនំវ សាគរោ
សា មេ វេស្សន្តរោ រាជា      បុត្តេទាសិ វនេ វសន្តិ ។

ជូជកោ អាហ ជូជកក្រាបបង្គំទូលថា បពិត្រអម្ចាស់តាមតែទ្រង់ព្រះមេត្តាប្រណី សេចក្តីទាំងនេះ ខ្ញុំពុំដឹងបើនឹងគិត តែដោយនូវពិតពុំមុសា ត្បិតព្រះអង្គគង់នៅព្រៃឆ្ងាយពន់ប្រមាណ សូមទានពុំចេរតែនឹងទ្រង់ព្រះមេត្តាអធ្យាស្រ័យ ។ យោ វេស្សន្តរោ ឯសម្តេចព្រះវេស្សន្តរពោធិវង្ស ព្រះអង្គតែងជាទីពឹងពំនាក់នៃមនុស្សសត្វតោកយ៉ាកលំបាកផងទាំងឡាយ ធរណីរិវ ដូចកលប្រឹថពី មួយសោតដូចកលសមុទ្រសាគរ រឺអស់សព្វសត្វផងទាំងឡាយ ក៏តែងអាស្រ័យព្រះអង្គ ដ៏មាននូវព្រះគុណជាឱឡារមហាឧត្តម ជាបឋមបរមក្សត្រឥតមានឯអ្នកណាមួយ ស្មើនឹងព្រះអង្គបាន ទើបព្រះរាជទានព្រះរាជកុមារទាំងពីរឱ្យមកខ្ញុំព្រះអង្គ ដោយនូវពិតឥតមុសាតាមតែទ្រង់ព្រះមេត្តាករុណាប្រណី ខ្ញុំតាជីចាស់ជរា នាកាលគ្រានោះឯងហោង ។

ឧក្កដ្ឋំ វត ភោ វញ្ញា      សម្មេធ ឃរមេសិធា

Websites: WatKhemaraRatanaram.org or WatKhmers.org

កថំ នុ បុត្តកេ ឧដ្ឋា អរញ្ញេ អវរុទ្ធកោ ។
ឥមំ ភោន្តោ និសាមេថ យាវន្តេត្ថ សមាគតា
កថំ វេស្សន្តរោ រាជា បុត្តជាសិ វនេ វសំ ។
ជាសំ ជាសិញ្ច សោ ឧដ្ឋា អស្សំ ចស្សតរីរថំ
ហត្ថិញ្ច កុញ្ជរំ ឧដ្ឋា កថំ សោ ឧជ្ជ ជារកេ ។

កាលនោះ អស់សេនាមាត្យផង បានស្តាប់ជូជកព្រាហ្មណ៍ ដោះសា ដោយដំណើរសេចក្តី យកព្រះមហាវេស្សន្តរជាបន្ទាល់ សាក្សី ក៏យល់ពិតពុំមុសា ទើបព្រមគ្នានិន្ទាថា ភោន្តោ នគរវាសិនោ ហៃអស់អ្នកនគរបណ្តានៅពិជ័យជេតុត្តរ យាវន្តេត្ថ សមាគតា អម្បាល អ្នកមកជួបជុំគ្នានៅនាឋាននេះទាំងប៉ុន្មាន សព្វេ តើអ្នកទាំងពួងញុំាង យល់នូវសេចក្តីដូចម្តេចហ៎ះ? និសាមេថ ចូរអ្នកពិនិត្យពិចារណា ដំណើរសេចក្តីនៃព្រះបាទស្រីវេស្សន្តរ ទុក្ខជំ ព្រះអង្គធ្វើអំពើកម្មពុំ តាមប្រពៃណីអំពីបុរាណរៀងមក សទ្ធេន ឃរមេសិនា កាលអំពីមុនពុំ ទាន់បានបួសជាឫសីមុនី នៅនៃព្រះស្រីពិជ័យជេតុត្តរនគរ សោយរាជ្យ សម្បត្តិ ម្តេចក៏កាត់ដំរីបច្ច័យនាគេន្ទ្រគជសារ ល្អត្រកាលជាតិកុញ្ជរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាទីនាំងសម្រាប់ព្រះនគរបវររាជធានីឱ្យទៅជាទាន ទើបបានគេក្រេវក្រោធអស់ទាំងព្រះនគរ បំបរបង់ឱ្យព្រាត់ព្រះញាតិវង្សា ទៅនៅអនាថាក្នុងព្រៃទូរដ្ឋាន ក៏អាល័យអ្វីតែនឹងទានមាល្បាយពុំដឹងស្ដាយកូនទាំងពីរនេះឡើយ ។ ពុំគិតប្រណី ឯព្រះហឫទ័យ ក៏កន្ទ្រឹសឫស្យាគួរឯណាក៏យកបុត្រឱ្យជាទានដូច្នេះហ៎ះ ធាសំ ធាសិញ្ច សោ ជដ្ឋា ឯធម្មតាប្រពៃណីក្សត្រ បើនឹងមានចិត្តកាត់តម្លាសទ្វាធ្វើទាន ក៏មានតែឱ្យនូវរាជយានរទេះដំរី ឱ្យខ្ញុំប្រុសស្រី របស់ទ្រព្យសព្វពិធរតន៍ផងទាំងឡាយ គាថំ សោ ជដ្ឋ ធារកោ អើអេះនេះ ម្ដេចក៏មកផ្ដាច់សាច់កូនឱ្យទៅជាទាន ពុំមានគិតឡើយ ។ អើអស់គ្នាយើងអើយ ព្រះបាទស្រីវេស្សន្តរនេះ អ្នកធ្វើឱ្យខុសសណ្ដាប់ច្បាប់ព្រះមហាក្សត្រ អំពីបុរាណរាជ្យរៀងមកនោះណាស់ហោង ។

កាលនោះ ព្រះជាលីកុមារជិនវង្ស ដ៏ទ្រង់នូវកតញ្ញុតា ដឹងគុណព្រះវររាជមាតាបិតា សុត្វា កាលណាបើឮអស់មុខមន្ត្រី គេស្រដីនិន្ទាដល់ព្រះបិតាដូច្នោះហើយ អសហន្តោ ពុំអាចដើម្បីនៅស្ងៀមបានឡើយ ទើបអ្នកឆ្លើយដោះសាការព្រះបិតា ឧបត្ថម្ភេន្តោ វិយ ឧបមា

Websites: WatKhemaraRatanaram.org or WatKhmers.org

បីដូចពិទ្យាធរដ៏ពូកែឆុតឆាប់ បាននិម្មិតនូវជើងដៃមួយពាន់ ឱបភ្នំព្រះសិនេរុរាជ ពុំឱ្យរលើងរលំជាចលាចល ព្រោះត្បិតខ្យល់ប្រល័យលោកបក់បោកមកពុំឱ្យអន្តរាយឡើយ ។ ទើបអ្នកក្រាបទូលអធិប្បាយសូត្រជាបាទព្រះគាថាដូច្នេះ ៖

យស្ស ជាស្ស ឃរេ ជាសោ អស្សោ ចស្សតរីរថោ
ហត្ថី ច កុញ្ជរោ ជាតោ តំ សោ ឧជ្ជា បិតាមហា ។

បិតាមហា បពិត្រសម្តេចព្រះរាជអយ្យកោអើយ ម្តេចឡើយក៏ពួកអាមាត្យនាំគ្នានិន្ទាសម្តេចព្រះវរបិតាខ្ញុំ ហេតុត្បិតអ្នកទៅនៅក្នុងព្រៃព្រឹក្សា យស្ស ជាស្ស ឃរេ ជាសោ នាកាលសម្តេចព្រះវររាជបិតាចេញចាកបុរី ពុំមានអ្វីជាទ្រព្យសម្បត្តិសព្វពិធរ័តន៍ ខ្ញុំប្រុសខ្ញុំស្រី ដំរីសេះ រទេះគោក្របី នឹងធ្វើជាទាន ដូចអស់ត្រកូលក្សត្រអំពីបុរាណរាជ្យរៀងមកឡើយ ។ បពិត្រសម្តេចព្រះអយ្យកោអើយ រីឯព្រះរាជហឫទ័យ សម្តេចព្រះវររាជបិតា តែងនឹងកាត់តម្លាសទ្វាធ្វើទានបានយល់តែមុខបុត្រាបុត្រី ជាពាហិរទានក្រៃលែងនឹងអស់ទានផងបាន ១០០ កម្លាំង តាំងព្រះរាជហឫទ័យនឹងដូរយកព្រះសព្វញ្ញុត-

Websites: WatKhemaraRatanaram.org or WatKhmers.org

ញ្ញាណឱ្យបានត្រាស់ជាព្រះពុទ្ធ តាមប្រពៃណីព្រះពុទ្ធអំពីបុរាណ ស្អាងព្រះបារមីទានតាមព្រះរាជហឫទ័យប្រាថ្នាឱ្យបានមគ្គផល ម្តេចឡើយក៏ពួកមនុស្សអកុសល មកត្មះតិះដៀលនិន្ទាដល់ព្រះវររាជបិតាខ្ញុំ មិនដឹងទេឬជាប្រទីបជ្វាលាកែវជាពន្លឺអស់សព្វសត្វ ម្តេចឡើយក៏មកស្តាប់ស្រដី ការអ្វីមកស្រដីឆោឡោអឺងកង ឯសម្តេចព្រះអយ្យកោតើយល់ព្រមដូចពាក្យអស់មុខមន្ត្រីហើយឬអ្វីណាអម្ចាស់ ។

កាលនោះ សម្តេចអយ្យកោ ទ្រង់ជ្រាបថាចៅជាលីតូចព្រះទ័យ ទើបព្រះអង្គប្រស្រ័យនូវពាក្យបរិហារ តាមដោយនូវព្រះប្រាជ្ញារម្ងាប់ក្តីក្រោធ យកទោសមកជាគុណថាដូច្នេះ ៖

ធានមស្ស បសំសាម ធាវនិន្ទាមិ ចោតក
កថំ នុ ហនយំ អាសិ តុម្ហេ ឧត្វា វនិព្វកោតិ ។

ចោតក ហៃជាលីដ៏ជាចៅសំឡាញ់អើយ អើអេះអ្នកនេះមិញហ្ន៎ ក៏មានប្រាជ្ញាដឹងអធ្យាស្រ័យ កុំអាលស្រដីក្រេវក្រោធធ្វើជាទោស ធាវនិន្ទាម អស់អ្នកទាំងឡាយសោត គេពុំរកកលកាច់កិនញុះញង់ចង់ត្មះតិះដៀលឪពុកអ្នកទេ បសំសាម គេសឹងតែសរសើរ

អស់ទាំងព្រះនគរ សាទរជួយអនុមោទនាថា ព្រះបិតាអ្នកនេះមានចិត្តកាត់តម្លាសទ្ធាប្រសើរពន់ប្រមាណ អាចយកបុត្រឱ្យទៅជាទានពុំមានរួញរា តុម្ហេ ទត្វា វណិព្វកេ នាកាលព្រះវររាជបិតា ឱ្យទានអ្នកមកជាទាសាទាសីនៃព្រាហ្មណ៍តាមប្រាថ្នា តើញុំាងសោមនស្សប្រិមប្រិយ ឬមានព្រះរាជហឫទ័យសៅហ្មងចងជាទោសពុំក្សេមក្សាន្ត ម្ដេចក៏ហ៊ានកាត់អ្នកឱ្យជាទានបាន ពុំមានអាល័យឡើយ ? ហៃចៅសម្លាញ់អើយ ចូរអ្នកប្រាប់ព្រះអយ្យកោឱ្យបានដឹងនាកាលឥឡូវនេះឯង ។

បិតា មយ្ហំ មហារាជ តុម្ហេ ទត្វា វណិព្វកេ
សុត្វាន កលុនំ វាចំ អច្ចកណ្ហាយ ភាសិតំ ។
ទុក្ខស្ស ហទយំ អាសិ អថោ ឧណ្ហំបិ អស្សសិ
រោហិណីហេវ តម្ពក្ខី បិតា អស្សូនិ វត្តយិ ។
យន្តំ កណ្ហាជិនាវោច អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត ធម្មិកា ហោន្តិ ព្រាហ្មណា
យក្ខោ ព្រាហ្មណវណ្ណេន ខាទិតុំ តាត នេតិ នោ

ជីយមានា បិសាចេន     កិន្នុ តាត ឧទិក្ខសីតិ ។

កាលនោះ ព្រះជាលីក្រាបបង្គំទូល សម្តេចព្រះអយ្យកោ អយ្យិកាអំពីនាងក្រស្នាពិលាបក្រាបទូលអង្វរព្រះវររាជបិតា ដូចមាន សេចក្តីនៅក្នុងកណ្ឌកុមារបព្វឯណោះ មកក្រាបបង្គំទូលសម្តេចព្រះ អយ្យកោ ឱ្យទ្រង់ព្រះសណ្តាប់សព្វគ្រប់ប្រការ ។

រាជា សញ្ជយោ រីព្រះបាទស្រីសញ្ជ័យ ព្រះអង្គយល់ ព្រះរាជនត្តានត្តា អមុញ្ចន្តេយេវ នៅជាទាសាទាសីនៃព្រាហ្មណ៍ នោះឯង ពុំលង់ឡើយព្រះអង្គត្រាស់ដណ្តឹងថា ៖

រាជបុត្តី ច មេ មាតា     រាជបុត្តោ ច មេ បិតា
បុព្វេ មេ អង្កមារុយ្ហ     កិន្នុ តិដ្ឋថ អារកាតិ ។

ហៃចៅជាលីក្រស្នាសម្លាញ់ជីតាអើយ អើព្រះជនកនៃអ្នក រាជបុត្តោ ក៏ជាពង្សវង្សក្សត្រាជាបុត្របណ្ឌូល រាជបុត្តី ទាំងព្រះមាតា ក៏ជាត្រកូលក្សត្រីកបកល្យាណីសុរិយវង្ស បុព្វេ ពីដើមអ្នកតែងទ្រង់ អស់គ្រឿងប្រដាប់អាត្មា បើបានយល់ព្រះអយ្យកោអយ្យិកា ក៏តែងនឹង ផ្តេកផ្តិត បើនឹងគាល់សោត ក៏ជិតពុំដែលឆ្ងាយ ឱ្យបានតែសប្បាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

តម្រេកព្រះហឫទ័យ ពីដូចចេញចាកព្រះអយ្យកោអយ្យិកា ទៅនៅព្រៃពុំទាន់ជាយូរបានប៉ុន្មានខែ ម្ដេចក៏មកប្រែខ្វៃប្លែងទាំងឥរិយាលំនាំ សមសារជាអ្នកក្រៅ ហាក់ដូចជាពុំដែលទៅមកស្គាល់គ្នា ហាក់ដូចមិនមែនសាច់ញាតិហ្ន៎ះ ។

ទើបព្រះជាលីកុមារ ក្រាបបង្គំទូលសម្ដេចព្រះអយ្យកោថា

រាជបុត្តី ច ទោ មាតា    រាជបុត្តោ ច ទោ បិតា
ទាសា មយំ ព្រាហ្មណស្ស    តស្មា តិដ្ឋាម អារកាតិ ។

បពិត្រព្រះអង្គ ដ៏ទ្រង់ព្រះមេត្តាប្រណី បើយើងខ្ញុំជាលីក្រស្នានេះ ជាត្រកូលខត្តិយវង្ស យើងខ្ញុំជាលីក្រស្នា ក៏អរនឹងព្រះគុណពន់ប្រមាណ នឹងយកអ្វីប្រៀបផ្ទឹមពុំបានឡើយ ទាសា មយំ បពិត្រអម្ចាស់អើយ តែយើងខ្ញុំនៅជាទាសាទាសីព្រាហ្មណ៍នៅឡើយ ក្រែងព្រះអង្គបានអាស្រូវភាសហើយ ក្រែងអស់មុខមន្ត្រីនូវអាណាប្រជានុរាស្ត្រគេត្មះតិះដៀលនិន្ទា ដល់ព្រះវររាជបិតា តស្មា តិដ្ឋាម អារកា យើងខ្ញុំខ្លាចព្រះចេស្ដាបារមី ទើបគាល់នៅតែពីចម្ងាយ ព្រោះសេចក្ដីតែប៉ុណ្ណេះឯងអម្ចាស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទើបព្រះបាទក្រុងស្រីសញ្ជ័យមានព្រះបន្ទូលថា ៖

មា សម្មេវំ អវចុត្ត    ឧយ្ហតេ ហទយំ មម
ចិតកាយំវ មេ កាយោ    អាសនេ ន សុខំ លភេ ។
មា សម្មេវំ អវចុត្ត    ភិយ្យោ សោកំ ជនេថ មំ
និក្ខិណិស្សាមិ ឧព្វេន    ន ហេ ទាសា ភវិស្សថ ។
កិមត្ថិយំ ហិ ហេ តាត    ព្រាហ្មណស្ស បិតា អទា
យថាភូតំ មេ អក្ខាថ    បដិចាទេន្តុ ព្រាហ្មណន្តិ ។

អើថៅជាលីសម្លាញ់ជីតាអើយ ម្តេចឡើយក៏ថៅចេះស្រដីថៃទាំចាំពាក្យពេចន៍សព្វសេចគ្រេចវាចា ហាក់បញ្ចៀសសត្រូវដល់ជីតានេះផងប៉ះ អវចុត្ត ជីតានេះនឹងសុំឃាត់អ្នក កុំឱ្យអ្នកស្រដីខ្ទីខ្ទាឱ្យឈឺផ្សាក្នុងចិត្ត ឧយ្ហតេ ហទយំ មម ប្រដូចអ្នកយកភ្លើងមកគរដុតឱ្យក្តៅក្រហាយ ចិតកាយំវ មេ កាយោ បីដូចយកជីតាទៅដាក់ក្នុងភ្លើងជើងថ្ករ ឱ្យរោលរាលឆុរឆេះជាពពុះផេះផង់ធូលី អាសនេ ន សុខំ លភេ ទោះនឹងដើរ នឹងដេក នឹងឈរ នឹងចុក ពុំមានសុខឡើយ ហៃថៅ

សម្លាញ់អយ្យកោអើយ អ្នកស្រដីនោះមិញស្មោះស្មើឱ្យជីតាជាទុក្ខសោកសល់អំពល់ក្នុងចិត្ត គិតដ៏មានច្បាប់ឯណាដែរឬ ក្សត្រាទៅជាខ្ញុំគេ ដូចអ្នកស្រដីនោះយល់ពុំសម សត្វហង្សនឹងច្រឡំដោយហ្វូងក្អែកយល់ប្លែកក្រៅវិស័យ **និរទោសា** ជីតានឹងលោះអ្នកឱ្យរួចចេញអំពីខ្ញុំព្រាហ្មណ៍ តាមតម្លៃកុំសង្ស័យបារម្ភក្រៀមក្រំក្នុងចិត្ត គិតជាទុក្ខពេកឡើយ **ភិមត្សិយំ** នាកាលព្រះបិតាអ្នក ឱ្យអ្នកជាទាសាទាសីនៃព្រាហ្មណ៍នោះ តើព្រះបិតាកាត់ថ្លៃប៉ុន្មាន ៗ ម្នាក់ហ្ន៎ះ **យថា ភូតំ** ចូរអ្នកក្រាបទូលជីតាឱ្យបានដឹងប្រាកដ **បដិចាទេន្តុ** សោះព្រះជីតាអផ្សុកជាទុក្ខក្នុងចិត្ត គិតនឹងឱ្យថ្លៃទៅយាចក ឱ្យស្រឡះសោះមានមន្ទិលណាចៅអើយ ។ ចៅជាលីស្តាប់ហើយក្រាបបង្គំទូលស្នងព្រះរាជឱង្ការថា ៖

**សហស្សគ្ឃំ ហិ មំ តាត ព្រាហ្មណស្ស បិតា អទា**
**អថុ កណ្ហាជិនំ កញ្ញំ ហត្ថិអាទិសតេន ចាតិ ។**

បពិត្រព្រះករុណា នាកាលសម្តេចព្រះវររាជបិតា ព្រះរាជទានខ្ញុំអម្ចាស់ ត្រាស់កាត់ថ្លៃថា **សហស្សគ្ឃំ** ជាសុវណ្ណ ១ ពាន់តម្លឹង តែថ្លៃខ្លួនខ្ញុំម្ចាស់ **កណ្ហាជិនំ កញ្ញំ** ឯនាងក្រស្នានារី **ហត្ថិ-**

Websites: WatKhemaraRatanaram.org or WatKhmers.org

អានិសង្សនេះ ៥ ព្រះអង្គកាត់ថ្លៃជាខ្ញុំប្រុស-ស្រី ដំរីសេះ រទេះគោឧសភរាជ មួយមុខមួយរយ ៗ នូវមាសឆ្អិនមួយពាន់តម្លឹងស្មើគ្នា ។

ទើបព្រះអង្គត្រាស់ថា អើប៉ុណ្ណោះទេឬ ទើបស្ដេចត្រាស់បង្គាប់ពួកភ្នាក់ងារថា ៖

ឧជ្ជេហិ កត្តេ តរមានោ　　ព្រាហ្មណស្ស អវាករ
ទាសីសតំ ទាសសតំ　　គវំ ហត្ថសកំ សតំ
ជាតរូបសហស្សញ្ច　　ចោតាទំ ទេហិ និក្កយំ ។
តតោ កត្តា តរមានោ　　ព្រាហ្មណស្ស អវាករិ
ទាសីសតំ ទាសសតំ　　គវំ ហត្ថសកំ សតំ
ជាតរូបសហស្សញ្ច　　ចោតាទំទាសិ និក្កយំ ។
ទាសីសតំ ទាសសតំ　　គវំ ហត្ថសកំ សតំ
អស្សតរីរថញ្ចេវ　　សព្វភោគេ សតំ សតំ
ជាតរូបសហស្សញ្ច　　ព្រាហ្មណស្ស ឧទេសិតោ
អច្ចាយិកស្ស លុទ្ធស្ស　　ចោតាទំទាសិ និក្កយន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

រឺឃ! ចៅភ្នាក់ងារ ចូរកុំឃូរ ទៅឱ្យឆាប់ ៗ យកទ្រព្យអំពីព្រះរាជឃ្លាំង ដោយភ្នាក់ងារទីទៃ ៗ អញនឹងឱ្យថ្លៃចៅអញ ព្រាហ្មណស្ស អភាគារិ ទើបអស់ភ្នាក់ងារ ឮព្រះរាជឱង្ការដូច្នោះហើយ ពុំឃូរឡើយ ក៏រត់ទៅវៃ ៗ យកមាសឆ្អិនពីរពាន់តម្លឹង និងខ្ញុំស្រី ១០០ ខ្ញុំប្រុស ១០០ គោបាព្រោះ ១០០ មេគោឆ្នាត់ ១០០ សេះ ១០០ រទេះ ១០០ មកឱ្យជូជកព្រាហ្មណ៍ស្រេចហើយ ទើបស្ដេចព្រះរាជទានប្រាសាទ ៧ ជាន់ ឱ្យជារង្វាន់ជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ នាកាលនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រឺអាថ៌ធម៌ឯណា ឧ ចាតកំ ពុំទាន់ប្រាកដ សត្ថា រឺព្រះសាស្ដាចារ្យ បកាសេន្តោ កាលព្រះអង្គសំដែង តំ អត្ថំ នូវអាថ៌នោះ ចាតកំ ឱ្យប្រាកដ អាហ ក៏ទ្រង់សូត្រជាអាថ៌បាទព្រះគាថាដូច្នេះ ៖

និក្ខិណិត្វា ច ធ្ជាបេត្វា ភោជយិត្វាន ធារកេ
សមលង្កវិត្វា ភណ្ឌេហិ ឧច្ចង្កេ ឧបវេសយុំ ។
សីសំ ន្ហាតេ សុចិវត្ថេ សព្វាភរណភូសិតេ
រាជា អង្កេ ករិត្វាន អយ្យកោ បរិបុច្ឆថ

Websites: WatKhemaraRatanaram.org or WatKhmers.org

កុណ្ឌាលេ ឃុសិតេ មាលេ    សព្វលង្ការភូសិតេ
រាជា អង្កេ ការិត្វាន    ឥទំ វចនមព្រវិ ។
កច្ចិ ឧភោ អរោគា តេ    ជាលិ មាតាបិតា តវ
កច្ចិ ឧញ្ឆេន យាបេន្តិ    កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា ច មកសា    អប្បមេវ សិរឹសបា
វនេ វាឡមិគាកិណ្ណេ    កច្ចិ ហឹសា ន វិជ្ជតីតិ ។

រាជា សញ្ជយោ រីឯព្រះបាទស្រីសញ្ជ័យ និត្ថិណិត្វា នាកាលព្រះអង្គលោះព្រះថៅទាំងពីរស្រេចហើយ ពុំលង់ឡើយ ស្តេចបីថ្នមលោមព្រះថៅទាំងពីរ ថើបព្រះសិរសាអង្អែលអស់អង្គ ទើបឱ្យព្រះញាតិវង្សព្រាន្ទូវអស់ព្រះស្នំ តូចធំ ជំទាវនាងខុនណាងផងទាំងឡាយ រៀបខ្វល់ខ្វាយទទួលព្រលឹងជាលីក្រស្នា សឹងតែស្រីកញ្ញាប្រឹមប្រិយ សឹងតែកូនមន្ត្រីល្អ ៗ ឧត្តម សមនូវរូបរាងបញ្ចង់ស្អាងអង្គ ប្រដាប់ប្រដាដោយនូវអាត្មាទីទៃ ៗ ស្រេចហើយនៃ ក្រាបថ្វាយបង្គំទូលថាំទទូលព្រះរាជឱង្ការ ហើយឱ្យជាលីក្រស្នាស្រង់ជំរះព្រះកាយបំបាត់ក្តៅក្រហាយ ឱ្យកើតសិរីសួស្តីមង្គលឧត្តម ទើបឱ្យអស់ស្រីព្រះស្នំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជម្រះដុសខាត់ព្រះអង្គ អស់ស្រីផងបបួលគ្នាត្រេកអរសោទរ ខ្លះយកទឹកសុគន្ធពិដោរស្រោចស្រពព្រះកាយ នាងខ្លះលើកព្រះឆាយឆ្លុះព្រះអង្គ ខ្លះយកសុគន្ធរសផាត់ផង់ភក្ត្រា ព្រះភីលៀងយកប្រេងប្រុងព្រះកេសាកេសី អស់អង្គព្រះរាជកុមារកុមារី សឹងពិដោរល្វេងល្វើយហើយទើបព្រះភីលៀងចុកចងព្រះកេសាកេសី ដ៏មាននូវរស្មីនោះរលេមរលង់ត្រចង់ត្រចះជ្រះថ្លា ភោជយិត្វាន នារកោ ប្រដាប់ព្រះរាជនត្តោនត្តាស្រេចហើយ ស្តេចឱ្យសោយភោជនាហារដ៏មានឱជារសសមលង្ក័រិត្វា ហើយទើបប្រដាប់ប្រដាព្រះរាជកុមារ ភណ្ឌោហិ ឱ្យទ្រង់គ្រឿងពិចិត្រនិងរត្នមណីភ្លឺព្រោងព្រាយ សុចិវត្ថេ ព្រះភូសាប៉ាក់ឆ្លាក់ជាកនកៈ ក្លាយឆាឆាយប៉ាក់ជាបញ្ចពណ៌យល់សក្តិសម កុណ្ឌលេទ្រង់នូវព្រះមកុដដ៏ឧត្តមថ្លៃថ្លា ប្រដាប់ប្រដានូវតាងគុលីកុត្រីស្មៀតសក់សុពណ៌បាទុក៏សឹងល្អរចនា យុសិតេ ឯព្រះហត្ថាទ្រង់នូវព្រះកងកច្រើនមានពណ៌ប្លែក ៗ ច្រាលឆ្អៅ មាលេ ទើបឱ្យសម្តេចព្រះថៅអ្នកទ្រង់នូវមាលា សញ្ចលង្ការភូសិតេ សឹងរចនាដោយកែវកែមផ្កា ក្រងចងប្រដាប់ព្រះរាជកុមារ ជាសង្ហារផ្ទិមអម្ពរយល់ប្រសើររុងរឿងទាំងពីរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រស់ស្រួលមុខគួរឱ្យអាសូរករុណា រាជា អង្គ៍ ការិត្វាន ទើបព្រះអង្គដ៏ជាឥសូរក្រុងពិជ័យជេតុត្តរបវររាជធានី ពព្រះជាលីចៅសម្លាញ់ ឯព្រះអយ្យិកាមិញពនាងក្រស្នា ទើបត្រាស់បង្គាប់ថា ឱ្យអស់អ្នកពិសេសឆ្វេងស្តាំទាំងឡាយ ឱ្យខ្វល់ខ្វាយរៀបរណ្តាប់អស់ភោជនាហារផងត្បិតអញនឹងរៀបចងព្រះហស្តចៅអញទាំងពីរ ។ សម្តេចព្រះអយ្យិកាក៏ត្រេកអរក្សេមក្សាន្ត ទើបបានរៀបបូជាគ្រោះរំដោះចង្រៃសារពើភ័យទុក្ខព្រួយឱ្យបានជាសុខសិរិទ្ធី ទើបត្រាស់ថា ស្រី ៗ ថ្ងៃនេះ ជាថ្ងៃសួស្តីឧត្តមជាបឋមឫក្សជា ។ សម្តេចព្រះអយ្យកោអយ្យិកា ព្រះញាតិវង្សាព្រមគ្នាស្រេចហើយ ទើបស្តេចហៅព្រលឹងជាលីក្រស្នាថា ព្រលឹងអើយ ចាប់ដើមតាំងអំពីព្រាត់ប្រាសចេញពីបុរីទៅនៅព្រៃ ជ្រោះជ្រលងដងស្ទឹងបឹងបួ ទួលទី យកតែខ្មោចព្រៃមកជាគ្នា យល់តែអស់ពាឡម្រឹគា ព្យគ្ឃ: សិង្ហសីហ៍ ដំរីប្រើស ទ្រាយទន្សាយខ្លោងខ្លា ។ ព្រលឹងអើយ នេះហេតុវេរាឱ្យព្រាត់ប្រាសចេញទៅ ឯព្រះអយ្យកោអយ្យិកា នៅរងតែទុក្ខស្រក់តែទឹកភ្នែកជានិច្ចកាល នឹងបរិភោគអាហារក៏ពុំមានរសពិសា ក្នុងទ្រូងក្តៅផ្សាដូចមនុស្សឥតវិញ្ញាណ ឮតែសព្ទ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពត៌មានបាន ៧ ខែនេះហើយ ទើបថ្ងៃនេះបានស្បើយដោះទុក្ខ ព្រោះបានឃល់មុខអ្នកជាចៅទាំងពីរ ។ ព្រលឹងអើយ កុំទៅសព្វជ្រោះជ្រលងដងស្ទឹង អ្នកកុំខឹងនឹងអយ្យកោអយ្យិកា ចូរអស់ខ្មោចព្រាយមកយកក្រយាបូជាគ្រឿងផង ឱ្យអ្នកបានគ្រងសព្វពិធវត្ថុសម្បត្តិរហ៍ពលហើយអស់កុសលព្រះអយ្យកោអយ្យិកា មកជួយពិភ័ក្តិរក្សាការគ្រងកុំឱ្យមានទុក្ខសោករោគភ័យផងទាំងឡាយ ។ ព្រលឹងអើយ កុំព្រាត់ប្រាសទៅអំពីអយ្យកោអយ្យិកា នូវព្រះញាតិវង្សា ឱ្យមានទីឃាយុយឺនយូរបាន ១០០ ព្រះវស្សា ឱ្យមានយសសក្តាធិការសម្ភារបារមី ឱ្យគ្រងពិជ័យជេតុត្តរស្នងព្រះវររាជមាតាបិតា ព្រះអយ្យកោអយ្យិកា ក៏នឹងបានផ្ញើខ្មោចលើអ្នកជាចៅ ។ ទើបអស់ព្រះស្នំក្នុងក្រៅ ក៏ឱ្យពរថ្វាយជ័យ អស់មុខមន្ត្រីហោរាព្រឹទ្ធាចារ្យ ក៏សឹងថ្វាយស័ព្ទសាធុការពរទ្រហឹងអឺងកង អស់ភ្លេងផងក៏ប្រគំអឺងអាប់ សមនូវស័ព្ទត្រែស័ង្ខ រគាំងភេរី តូរ្យតន្ត្រីថ្វាយជ័យព្រះរាជកុមារទាំងពីរអង្គន៉ុះឯងហោង ។

រីសម្ដេចព្រះអយ្យកោអយ្យិកានូវព្រះញាតិវង្ស កាលណាបើបានថ្វាយជ័យព្រះរាជកុមារស្រេច នូវប្រការអម្បាលនោះហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុំលង់ឡើយ ទើបត្រាស់ដណ្តឹងព្រះជាលីថា ព្រះជនកព្រះជននីអ្នកទៅនៅព្រៃ តើញុំាងប្រស័យផ្លែឈើមើមឈើ នូវសារពើបណ្ណាការជាអាហារបរិភោគផ្សារព្រៃ តើញុំាងប្រស្រ័យបានឬទេ មួយសោតពាឡម្រឹគាសឹងសាហាវយង់ឃ្នង តើញុំាងមកបៀតបៀនពាធាយាយីឱ្យជាទុក្ខពុំសុខក្បែរមក្សាន្ត ឬឥតអង្គឹមានឡើយ ហើយបានសេចក្តីលំបាកតោកយ៉ាកធូន់ស្រាលមានប្រការនោះ ម្តេច ៗ ណាចៅអើយ ចៅកុំលាក់ឡើយ ចូរចៅក្រាបទូលព្រះអយ្យកោអយ្យិកា នាកាលឥឡូវនេះឯងហោង ។

ទើបព្រះជាលីកុមារ ក្រាបទូលអំពីទុក្ខសោករោគភ័យ នូវសេចក្តីលំបាកសព្វសេចគ្រេច អំពីសម្តេចព្រះវររាជមាតាបិតា នៅនាព្រៃព្រះហេមពាន្ត មកនិទានថ្វាយសម្តេចព្រះអយ្យកោអយ្យិកា ប្រាថ្នាឱ្យស្តេចលើកអស់រេហ៍ពលសកលយោធា ចេញទៅអារាធនាសម្តេចព្រះវររាជមាតាបិតា ឱ្យវិលមកគ្រងព្រះនគរ នាកាលគ្រានេះ ទើបព្រះជាលីកុមារក្រាបបង្គំទូលថា ៖

អថោ ឧភោ អរោគា តេ ទេវ មាតាបិតា មម

អថោ ឧញ្ឆេន យាបេន្តិ អថោ មូលផលា ពហូ
អថោ ឌំសា មកសា ច អប្បមេវ សីរីសបា
វនេ វាឡមិគាកិណ្ណា ហឹសា នេសំ ន វិជ្ជតិ ។
ខណន្តាលុកលម្ពានិ វិឡាលិតក្កលានិ ច
កោលំ ភល្លាតកំ ពេលំ សា នោ អហាច្ចចោសតិ ។
យញ្ចេវ សា អាហាតិ វនមូលផលហារិយា
តំ នោ សព្វេ សមគន្ត្វា រត្តឹ ភុញ្ជាម នោ ទិវា ។
អម្មា ច នោ កិសា បណ្ឌុ អាហរន្តី ទុមប្ផលំ
វាតាតបេន សុខុមាលី បទុមំ ហត្ថគតមិវ ។
អម្មាយ បតនូកេសា វិចរន្ត្យា ព្រហាវនេ
វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ ។
កេសេសុ ជដំ ពន្ធិត្វា កច្ឆេ ជល្លមធារិយ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតីតិ ។
បិតាមហា បពិត្រសម្តេចព្រះអយ្យកោអយ្យិកាជាអម្ចាស់

អើយ វីព្រះវររាជមាតាបិតានៃយើងខ្ញុំនោះ ព្រះអង្គគង់ជាសុខសប្បាយផ្សាជាអ្នកកំសត់ទុគ៌តអត់ឃ្លាន ។ អម្ចាស់អើយ ទ្រង់តែងតែស្វែងរកផ្លែឈើមើមឈើនោះសឹងមានច្រើន ។ មួយសោត វីមូសទាក ស្រាំង ស្រួយ ក្អែបខ្វួយ មមង់មមាច កន្ទេចអាល នូវសារពើពស់តូចពស់ធំប្រទុំនីទៅនូវម្រឹគផងទាំងឡាយជាដើម គឺខ្លាតូច ខ្លាធំ ខ្លាឃ្មុំ ខ្លាដំបង ទន្សាយ ទន្សោង រមាស រមាំង គោព្រៃ រាជសីហ៍ ដំរី សិង្ហសឹងដ៏ស្រែកទ្រហឹងអឹងអាប់ ឮសព្ទសំឡេងទាំងយប់ទាំងថ្ងៃ សឹងតែសាហាវពន្លឹក តែគឺមោះឥតមកបៀតបៀនក្សត្រទាំងពីរព្រះអង្គ ដោយនូវតេជះដែលទ្រង់តែងចំរើនមេត្តាភាវនា មួយសោត គួរអាសូរព្រះមេនៃយើងខ្ញុំ ព្រះអង្គទ្រង់ចងព្រះកេសាជាតាបសឫសី ទន្ទឹងតែព្រឹកព្រហាមស្រាងស្រេចឡើងហើយ ស្តេចទ្រង់យកនូវកញ្ជើ សង្រែកដងរែក ជ្រនីកទំពក់ ស្តេចត្រាច់ដើរចូលព្រៃ អាស្រ័យស្វែងរកជីក ដំឡូងដូង ដំឡូងដៃខ្លា ដំឡូងស្បា ដំឡូងទៀន ដំឡូងពងប្រវឹក ដំឡូងពងលលក ហើយដើររកបេះប្រឡេះថ្លក់យកនូវផ្លែស្រគំ គុយ គូលេនទុរេន ដូង ស្លា មង្ឃុត ល្មុត សេដា នូវអស់ផ្លែឈើផងទាំងឡាយ ទុក

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្នុងកញ្ជើ ហើយរែកនាំមកចិញ្ចឹមយើងខ្ញុំទាំងបីអង្គ នៅនាអាស្រមបរម សាលានោះហោង ។

បពិត្រព្រះជីតាអម្ចាស់ខ្ញុំអើយ រីព្រះនាងមទ្រីជាព្រះមេនៃ យើងខ្ញុំ មុខគួរឱ្យអាសូរក្រៃពេក ទន្ទឹងតែព្រឹកឡើងហើយ ស្តេចដើរ ចូលព្រៃស្វែងរកផ្លែឈើមើមឈើ ដ៏មានសម្បុររាងកាយនោះស្គម លឿង ដោយត្រូវថ្ងៃ ព្រោះអ្នកធ្លាក់តែនៅស្រណុកសុខសប្បាយ លុះ ព្រះមេនៃយើងខ្ញុំដើរចូលព្រៃណាស់ទៅ ក៏មានព្រះកេសានោះជ្រុះ ស្កើងរលើងដោយសសិតវារីតរួត ហើយជាប់ជំពាក់នឹងមែកព្រឹក្សាផង ព្រះមេនោះមានសម្បុរជាំដាំរលាករលោច ដូចផ្កាឈូកដែលគេកាន់ ឈ្លី ។ បពិត្រព្រះជីតាអើយ រីសម្បុរព្រះមេនៃយើងខ្ញុំ ក៏មានឧបមាដូច ផ្កាឈូកនោះ ។

រីព្រះជាលីកុមារ ក្រាបទូលពីដំណើរទុក្ខព្រះវរមាតា នូវ ប្រការអម្បាលនោះ ហេតុតែមានព្រះហឫទ័យរលឹក ព្រះវរមាតា ច្រើនក្តាត់ ហើយមានបំណងចង់ឱ្យព្រះអយ្យកោអយ្យិកា ទៅអញ្ជើញ មកកូវ ទើបព្រះជាលីកុមារពោលចោទព្រះអយ្យកោអយ្យិកា សូត្រជា

Websites: WatKhemaraRatanaram.org or WatKhmers.org

បាទព្រះគាថាដូច្នេះ ៖

បុត្តា បិយា មនុស្សានំ លោកស្មឹ ឧបបជ្ជិសុំ
ន ហិ ឆ្វន្នម្ហាកំ អយ្យកស្ស បុត្តេ សិនេហោ អជាយថាតិ ។

បពិត្រព្រះជីតាអម្ចាស់អើយ ដូចយើងខ្ញុំសូមក្រាបបង្គំទូល ឥឡូវនេះ ធម្មតាកូនប្រុសស្រី ដែលកើតមកនាលោកិយនេះ រមែងជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ចុះឯព្រះបាទស្រីវេស្សន្តរ ព្រះវររាជបិតានៃយើងខ្ញុំ ម្រាងពុំមែនជាព្រះរាជបុត្រអម្ចាស់ទេឬ ទើបអម្ចាស់ពុំសព្វព្រះរាជហឫទ័យ អាល័យអាសូរករុណាដល់តិចឡើយ។

រីព្រះបាទស្រីសញ្ជ័យ ស្តេចទ្រង់ព្រះសណ្តាប់ពាក្យ ព្រះជាលីកុមារ ក្រាបទូលដូច្នោះហើយ ក៏ស្តេចនឹករលឹកទោសរបស់ព្រះអង្គជាក់ច្បាស់ ទើបត្រាស់ថា ៖

ទុក្កដញ្ច ហិ នោ ចោត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសឹ អទូសកំ ។
យំ មេ កិញ្ចិ ឥធ អត្ថិ ធនំ ធញ្ញញ្ច វិជ្ជតិ
ឯតុ វេស្សន្តរោ រាជា សិវិរដ្ឋេ បសាសតូតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ចោតក ម្នាលចៅសំឡាញ់ជីតាអើយ ហេតុតែជីតាយកពាក្យអ្នកស្រីពិរាស្រ្តបំបរបង់បិតាបា ឱ្យចេញទៅនៅនាភ្នំគិរីវង្កត រីអំពើនោះហៅថា ជីតាធ្វើខុសឆ្គងណាស់ ក៏ឥឡូវនេះជីតានឹងប្រើបាឱ្យនាំអស់ពលសកលយោធាផង ចេញទៅអារាធនាព្រះបិតាបា មកសោយរាជ្យសម្បត្តិ បិតជាឥស្សរកំពូលលើអស់រាស្រ្តផងទាំងឡាយ នៅនាក្រុងពិជ័យជេតុត្តរមហានគរវិញហោង ។

ក្សិណនោះ ព្រះចៅជាលីកុមារ បានស្តាប់ព្រះបន្ទូលព្រះជីតាហើយ ក៏មានចិត្តអំណរត្រេកអរមហិមា ទើបក្រាបបង្គំទូលវិញថា

ន តេ មយ្ហំ វចោ ឯហិតិ សិរិសុត្តមោ
សយមេវ តេហេ គន្ត្វាន សិញ្ច ភោគេហិ អត្រជន្តិ ។

បពិត្រព្រះជីតាអម្ចាស់ខ្ញុំអើយ នាអម្ចាស់មានព្រះតម្រាស់ដូច្នោះនោះ ស្មោះឆ្ពោះពីរោះពេកណាស់ រីសម្តេចព្រះវររាជបិតានៃយើងខ្ញុំនោះ ព្រះអង្គទ្រង់នូវព្រះប្រាជ្ញាច្រើនពេកក្តាត់ ធ្វើម្តេចឡើយព្រះអង្គនឹងយកពាក្យអញខ្ញុំជាក្មេងតូចដូច្នេះ ។ សូមអម្ចាស់ស្តេចលីលាទៅអញ្ជើញដោយព្រះអង្គឯង ហើយស្តេចប្រគល់ថ្វាយរាជ្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្បត្តិដល់ព្រះវររាជបិតាអញខ្ញុំនោះ ប្រាកដជាស្តេចនឹងថ្កានរាជបុរី ពិជ័យជេតុត្តរវិញពុំខាន ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រីអាថ៌ធម៌ឯណា ន ចាគជំ មិនទាន់ប្រាកដ សត្ថា រីព្រះសាស្តាចារ្យ បកាសេន្តោ កាលព្រះអង្គសម្តែង តំ អត្ថំ នូវអាថ៌ធម៌នោះ ចាគជំ ឱ្យប្រាកដ អាហ ក៏ព្រះឈ្មះមារាធិរាជ អាចបន្ទូលសានូវអាថ៌បាទព្រះគាថាដូច្នេះ ៖

| | |
|---|---|
| តតោ សេនាបតី រាជា | សញ្ជយោ អជ្ឈភាសថ |
| ហត្ថី អស្សា រថា បត្តិ | សេនា សន្នាហយន្តុ នំ |
| នេគមា ច មំ អន្វេន្តុ | ព្រាហ្មណា ច បុរោហិតា |
| តតោ សដ្ឋី សហស្សានិ | យោធិនោ ចារុទស្សនា |
| ខិប្បមាយន្តុ សន្នទ្ធា | នានាវណ្ណេហិលង្កតា ។ |
| និលវត្ថធរានេកេ | បីតានេកេ និវាសិតា |
| អញ្ញេ លោហិតឧណ្ហីសា | សុទ្ធានេកេ និវាសិតា |
| ខិប្បមាយន្តុ សន្នទ្ធា | នានាវណ្ណេហិលង្កតា ។ |

Websites: WatKhemaraRatanaram.org or WatKhmers.org

ហិមវា យថា គន្ធេភ បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ មហាភូតគណាលយោ ។
ឱសធេហិ ច ទិព្វេហិ ទិសា ភាតិ បវាតិ ច
ខិប្បមាយន្តុ សន្នទ្ធា ទិសា ភន្តុ បវន្តុ ច ។
តតោ នាគសហស្សានិ យោជយន្តុ ចតុទ្ទស
សុវណ្ណកច្ឆេ មាតង្គេ៍ ហេមកប្បនិវាសសេ ។
អារុឡ្ហ គាមណីយេភិ តោមរង្កុ៍សបាណិភិ
ខិប្បមាយន្តុ សន្នទ្ធា ហត្ថិក្ខន្ធេហិ ទស្សិតា ។
តាតោ អស្សសហស្សានិ យោជយន្តុ ចតុទ្ទស
អាជានិយេវ ជាតិយេ សិន្ធវេ សីឃវាហនេ ។
អារុឡ្ហ គាមណីយេភិ ឥន្ទិយាចាបធារិភិ
ខិប្បមាយន្តុ សន្នទ្ធា អស្សបិដ្ឋេ អលង្ក៍តា ។
តតោ រថសហស្សានិ យោជយន្តុ ចតុទ្ទស
អយោសុកតនេមិយោ សុវណ្ណចិត្រចោក្ខរេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អាពេបេន្តុ ជជេ តត្ថ ចម្មានិ ការចានិ ច
វិច្ឆាលេន្តុ ច ចាចានិ ជឡ្ហជម្មា បហារិនោ
ទិប្បមាយន្តុ សន្នទ្ធា រថេសុ រថជីវិនោតិ ។

រាជា សញ្ជយោ បពិត្រអើយ ឮដ៏កាលនោះព្រះបាទស្រី សញ្ជ័យ ព្រះអង្គបានជ្រាប អំពីព្រះជាលីកុមារក្រាបទូល ដោយនូវ ដំណើរសេចក្ដីលំបាកនៅក្នុងព្រៃ ក៏ទ្រង់ប្រណីអាសូរករុណា ដល់រាជ បុត្រីបុត្រាពន់ប្រមាណ អជ្ឈភាសថ ទើបមានព្រះរាជឱង្ការបង្គាប់មុខ មន្ត្រីចតុស្តម្ភ តាមដោយនូវភ្នាក់ងារ ភោ អមច្ចា ហៃអស់សេនា មាត្យផងទាំងឡាយអើយ ចូរព្រះស្តែងតាក់តែងសំបុត្រ តាមដោយនូវ កំណត់រាជការមុខក្រសួងទីទៃឆាប់ ៗ រ៉ៃ ៗ រៀបប្រដាប់ប្រដា ត្បិត អញនឹងយាត្រាទៅឯភ្នំគន្ធមាទន៍ អារាធនាសម្តេចព្រះឱរសា ឱ្យលា ព្រតចេញអំពីឥសីនិងប្រគល់បុរីរាជដ្ឋាន ហើយនឹងបានអភិសេកឯក ឧត្តមបរមក្សត្រ នាកាលគ្រានោះឯង ខេតមា ច មំ អន្វេន្តុ ចូរអាជ្ញានាំ ព្រះរាជឱង្ការទៅប្រាមប្រាប់អស់ចៅហ្វាយស្រុក ឯក ទោ ត្រី ចត្វា បណ្តាមាននៅស្រុកក្រៅ លំនៅជនបទនានា ខ្មែរ ភូមា មន ង៉ូវ ឱ្យមក

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្មោះសរជួបជុំឱ្យរៀបប្រដាប់ប្រដា តាមដោយប្រទេសភាសាភ្នាក់ងារ ចាម ជ្វា វិលន្ទា លង្កា អង្គ្លេស ពទ៌ុគេស អារ៉ាប់ ចិន ចាមព្រាហ្មណ៍ កូឡា ហង្សា យួន ជប៉ុន សឹងដ៏គ្រប់គ្រាន់ព្រមព្រើសសព្វប្រទេសភាសា សន្ទទ្ធា ចូរប្រដាប់ឱ្យមានសិរីសួស្តី ពិជ័យសង្គ្រាមតាមយោគយាមយាត្រា ។ ឯអស់យោធាទាំងមួយម៉ឺនបួនពាន់ សឹងដ៏ហានក្លា មានថ្វីដៃធ្វើសឹក មានជ័យជំនះឈ្នះអស់សត្រូវបាក់បបខ្លបខ្លាច អាចអង្គនីរព័ទ្ធ ខ្លះក៏ស្ទាត់ឯខាងសណ្តំ ខ្លះកាន់អាគមមហាបាំងងាំងបំបាំងកាយ ខ្លះកាន់មហារលាយរលួយសឹង ដ៏ឆុត ៗ ខ្លះកាន់មហាទល់ហាត់មើលមេឃឆាយ ខ្លះកាន់ទាំងព្រាយ បញ្ចៀសគង់ប្រេះ សឹងដ៏មានតបះពុំក្រែងខ្លាច អាចចូលកណ្តាលសឹកសាម តាមកាត់ក្បាលសត្រូវពុំមានភ្លឹក ខ្លះចេះព្យូហ៍សឹកឧបាយកលដោយនូវលោមឱ្យសត្រូវទាំងពួង បាក់បបខ្លបខ្លាច ដោយនូវអំណាចចេស្តា ។ រ៉ឺយ ៗ អស់យោធាផងទាំងឡាយ អម្បាលដែលកើតថ្ងៃជាមួយនឹងកូនអញចារុឧស្សរជា ដ៏មានអាត្មាល្អឆើតឆាយ អម្បាលនៅស្រុកជិតឆ្ងាយសព្វតំបន់ សន្ទទ្ធា ចូរឱ្យរៀបគ្នាដោយនូវចំពូកឆ្វេងស្តាំ ជាជារឈ្មោហិ-

Websites: WatKhemaraRatanaram.org or WatKhmers.org

លង្កិតា យោធាមួយជំពូកវិញទៀត ឱ្យមានកំណត់ស្លៀកពាក់សំពត់និលពស្ត្រឋានខ្មៅ បញ្ចុះនីទៅនូវលេខយន្តមហាអង្គរក្ស សឹងដ៏ប្រសិទ្ធិសក្តិចេស្តា អាចការសារពើអាវុធក្នុងសង្គ្រាមដ៏មានដៃកាន់នីទៅនូវទូនកៅទណ្ឌ ស្ទុះលោតរន្ទាន់ចេញទៅ **បីតានេកោ និវាសិតា** យោធាធំជំពូកមួយវិញទៀត ឱ្យស្លៀកសំពត់កោសេយ្យពស្ត្រឋានលឿង ពាក់អាវផាយយល់ល្អវិសេសឧត្តមសមនូវផ្កា ក្លែបក្លាយលាយបញ្ចពណ៌ យល់ពព្រាលពព្រាយ យល់ត្បូងពិទាយបទុមរាគរ័តន៍គិតដ៏អ្នកថ្លៃជាឡើរយល់ល្អថ្លៃថ្លា ។ យោធាមួយចំពូកវិញទៀតកាន់ខែលមាស មានក្បូរក្បាច់រំលេចលួសលាយបញ្ចពណ៌យល់សក្តិសម **សុទ្ធានេកោ និវាសិតា** យោធាមួយចំពូកវិញទៀត ឱ្យស្លៀកសំពត់ខោមពស្ត្រឋានស ល្អឧត្តមសមនឹងយសសក្តា **ហិមវា យថា** ឧបមាបីដូចព្រៃហេមពាន្ត ជាឋានបរិវារនៃភ្នំគិរីវង្កត សឹងដ៏មានទំហំខ្ពស់ធំទ្រង់នូវសុគន្ធរស ១០ ប្រការ ប្រកបនូវព្រឹក្សាផលាហារ ពុំដឹងបើនឹងគណនា ។ ព្រឹក្សាដ៏ដុះស្រោងស្រោងស្រឹង ត្រឈឹងត្រសុំត្រសាយមហាភូតតណោលយោ ជាទីពំនាក់ទេវតា ពិទ្យាធរកិន្នរ ឥន្ទព្រហ្ម

Websites: WatKhemaraRatanaram.org or WatKhmers.org

យមយក្ស គ្រុឌនាគផងទាំងឡាយ តែងនឹងក្រសាលសប្បាយ ជាទីលំនៅកបនីទៅនូវសព្វពិធវ័ត្ថ កែវកងពៃទូរ្យស្វរ្យកាន្ត សឹងដ៏មានរស្មីភ្លឺព្រោងព្រាយ យថា នោះតើឧបមាដូចម្តេច តេ យោធា រីឯអស់យោធាស្តេចឱ្យប្រដាប់សម្រាប់កាយ យល់ល្អឆើតឆាយផ្សេង ៗ ដោយនូវពណ៌ទីទៃ ៗ ប្លែក ៗ ពីគ្នា ឧបមាបីដូចព្រៃហេមពាន្តនោះឯងហោង ។

ភោ អមច្ចា ហៃអាមាត្យទាំងឡាយអើយ រីអស់ទាហានសេនាអម្បាលរក្សាបម្រុងរាស្ត្រ នៅក្នុងព្រះនគរ នូវអស្សតរសិន្ធពគ្រប់ទាំង ១ ម៉ឺន ៤ ពាន់ សឹងដ៏ល្អឧត្តមសមនូវលក្ខណា កាយានោះវែងជរជាយមានកន្ទុយធំយារ ភ្នែកមូលស្អាត មានមារយាទនោះល្អអាជានីយេ គិតដ៏ជាអាជានេយ្យដឹងចូលចេញដេញថយពុំព្រួយប្រើបើនឹងធាក់នឹងខាំក៏ឥតខ្លាចក្រែងសឹកសត្រូវ បើនឹងបរបំផាយចូលទៅក៏ឆៀបឆាប់ប្រញាប់រួសរាន់ទាន់ចិត្ត សិន្ធវេ គិតដ៏ជាសេះសិន្ធពមានត្រកូលអំបូរមានទាំងកម្លាំង ឡើងទាំងសម្បុរខៀវ ស ល្អប្លែក ៗ មានសម្រែកនោះខ្លាំង អារុឡ្ហា មានទាំងនាយសារថី ជិះជាន់តាមក្បួនដៃកាន់ទួនកៅទណ្ឌកែក្រោយ រីឯប្រដាប់កាយពាជី សឹងដ៏ល្អឧត្តម

Websites: WatKhemaraRatanaram.org or WatKhmers.org

ឃ្លុំបង្អៀររឹតអុករឹតថោងខ្សែហោងខ្សែហាង សងខាងប្រដាប់ប៉ែកឈ្នាន់ ខាន់ជីបគ្រីបប៉ាក់សឹងដ៏ល្អថ្លៃថ្លា សឹងដ៏សុវណ្ណាប្រដាប់នូវរ័តន៍រាយផ្កាយ ស្លឹកពោធិ៍បុស្សនាំងមានទាំងកណ្តោលឈ្នាន់ជិះជាន់ បើកបរប្រយ័ត្នការសារពើអាវុធក្នុងសង្គ្រាម ឥន្ទិយាចាបជាវិកិ ដ៏មានដៃកាន់នីទៅនូវទូនកៅទណ្ឌ ចូរប្រដាប់ឱ្យគ្រប់គ្រាន់ ឱ្យបានទាន់អញនឹងចេញទៅនាកាលឥឡូវនេះឯងហោង ។

លាជា ឱលោភិយា បុច្ឆា មាលាគន្ធវិលេបជា
អគ្គិយានិ ច តិដ្ឋន្តុ យេន មគ្គេន ឯហិតិ ។
គាមេ គាមេ សតំ កុម្ភា មេរយស្ស សុរាយ ច
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ
មំសា បូវា ច សង្កុល្យា កុម្មាសា មច្ឆសំយុតា
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ ។
សប្បិ តេលំ ទធិ ខីរំ កង្គុបិដ្ឋា ពហូ សុរា
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អាឡារិកា ច សូទា ច　　នដនដ្តកគាយិនោ
ចាណិស្សរា កុម្ភថូនិយោ　　មុទ្ទិកា សោកជ្ឈាយិកា ។
អាហញ្ញន្តុ សព្វវីណា　　ភេរិយោ ឌិណ្ឌិមានិ ច
ខរមុខានិ ធមន្តុ　　នទន្តុ ឯកចោក្ខរា ។
មុទិង្គា បណ្ឌវា សង្ខា　　គោធា បរិវទន្តិកា
ឌិណ្ឌិមានិ ច ហញ្ញន្តុ　　កុដុម្ពា ឌិណ្ឌិមានិ ចាតិ ។

រាជា សញ្ជយោ ឯព្រះបាទស្រីសញ្ជ័យ ស្ដេចមានព្រះរាជហឫទ័យត្រេកអរមហិមា ស្ដេចបង្គាប់យោធាផងទាំងឡាយ ឱ្យខ្វល់ខ្វាយជម្រះមាគ៌ា ដែលស្ដេចនឹងលីលាទៅ ។ រីឯទទឹងផ្លូវឱ្យបាន ៨ យោបំគោឧសភរាជ កុំឱ្យខ្ពស់កុំឱ្យទាប ឱ្យរាបដូចផ្ទៃស្គរ ឱ្យមានភ្នាក់ងារសង់ព្រះពន្លានៅទីតំណាក់ លុះដល់ទីដាក់ឱ្យបាន ៣ យោជន៍ស្ដេចគង់ស្រង់សោយឱ្យមានព្រះតំណាក់ស្ដេចគង់បញ្ឈប់ ឱ្យមានគ្រប់ទាំងរោងដំរី លាជា ឱលោកិយា ហើយប្រដាប់ប្រដាពាសសឹងពិតានស ឱ្យល្អបរិសុទ្ធ ឱ្យក្រាលក្រងចងនីទៅនូវផ្កាភ្ញី មាននូវលាជបាចរាយជុំឋាន ឱ្យមានទង់ជ័យចាមរ បៃមន់ សែងត្ងូន អភិរម្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

មាលាគន្ធវិលេបនា ឱ្យមាននូវគ្រឿងពិដោរ គឺសុគន្ធរសស្រស់ប្រពៃ សម្រាប់នៅនៃរោងទឹកស្រង់ ហើយឱ្យសង់រន្ទាភ្លើងដោយនូវពណ៌ ទីទៃ ៗ នច្ចគីតវាទិតោ ឱ្យមានតូរ្យតន្ត្រីពិណពាទ្យប្រគំ សម នូវសព្ទចម្រៀងរាំបំរើ ចាណិស្សរោ សារពើកំប្លែងដោយនូវពណ៌ ល្បែងផ្សេង ៗ ឱ្យគ្រប់ សោភគ្គាយិកា ឱ្យមានសព្ទសារពើល្បែង សម្រាប់ច្រៀងរាំ សឹងជំខ្វែនស្នាត់ស្ញព្រ័ត្របាក់ដារប៉ាវខុន ខោលយន្ត ជើតល្បែងផ្សេង ៗ លោតកញ្ឆេង ម៉ូងគ្រុំផ្គាគូ ផ្គារាយ នាងក្រាយប្រះ ស្មិល ពាំត្បាល់ ប្រដាល់ប្រកាប់ចំបាប់ត្រីវិស័យគ្រប់ល្បែងមហោស្រព សំរាប់អភិសេក ឱ្យមានសព្វគ្រប់កុំឱ្យខ្វះឡើយ សតំ កុម្ភា ឱ្យភ្នាក់ងារ ដាក់សារពើអាហារ នៅរៀងសងខាងមាគ៌ា ដែលស្តេចនឹងលីលា ដោយនូវផ្លូវដល់មាត់ទ្វារព្រៃ ឱ្យបានអស់ពលអាស្រ័យបរិភោគ មច្ឆ សំយុត្តា ឱ្យអស់ភ្នាក់ងារប្រដាប់ប្រដា មច្ឆមំសាអាហារឱ្យគ្រប់គ្រាន់ សប្បិ តេសំ ឧជិ ខីរំ ទាំងប្រេងម្សៅសឹងក្លិនពិដោរឈ្ងុយឈ្ងប់ ដាក់ សម្រាប់នៅខាងផ្លូវ ដែលអញនឹងទៅឯព្រះរាជបុត្រអញ ឯភ្នំគិរីវង្កត នោះឯង ។ នាកាលព្រះបាទស្រីសញ្ជ័យនរេន្ទ្រាធិបតីស្រីសុរិយោវង្ស

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គឱ្យរៀបអស់រេហ៍ពលសកលយោធាស្រេច ស្ដេចនឹងយាត្រាចេញទៅភ្នំគិរីវង្កតបពិតរាជដ្ឋាន នាកាលគ្រានោះឯងហោង ។

ជូជកោ បមាណាតិក្កន្តំ ភុញ្ជិត្វា បពិត្រអើយ រីជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ គាត់យល់ចំណីភោជនាហារដែលស្ដេចព្រះរាជទានផ្សារ ដោយជូជកគាត់ទើបមឹងមកអំពីអត់ឃ្លាន ហើយគាត់ជាមនុស្សឥតខ្មាស បរិភោគទាល់តែចាក់ច្រាស ចើសលើសចុងដង្ហើមមើលទៅគួរតែស្ញើម នឹងភ្នែកគាត់ស្លើតស្លក់ តេជោធាតុនឹងបក់ឱ្យឆេះរលួយអាហារពុំទាន់ ជូជកគាត់បែកពោះស្លាប់ នាកាលនោះឯងហោង ។

អថ រាជា តស្ស សរីរកិច្ចំ ការាបេត្វា បពិត្រអើយ ឮដ៏កាលនោះព្រះបាទស្រីសញ្ជ័យ ស្ដេចធ្វើបុណ្យរំលាយសពតាជូជកនោះហើយ ទើបស្ដេចឱ្យរាជអាមាត្យប៉ាវគង សួររកញាតិផៅពង្សរបស់ជូជកសព្វស្រុកជាគំរប់ ៧ ថ្ងៃ ក៏ឥតមានអ្នកឯណាមួយ ទទួលជាញាតិសន្តានរបស់ព្រាហ្មណ៍នោះឡើយ ។ រីអស់ព្រះរាជទ្រព្យអម្បាលនោះ ដែលលោះព្រះរាជកុមារនោះមិញ ក៏បង្វិលមកជាព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

រាជទ្រព្យវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូល សូត្រសាន្ទូវបាទព្រះគាថាទាំងឡាយដូច្នេះ ៖

សា សេនា មហតី អាសិ   ឧយ្យុត្តា សិរិភាហិនី
ជាលិនា មគ្គនាយេន   វត្តំ ចាយាសិ បព្វតំ ។
កោញ្ចំ នទតិ មាតង្គោ   កុញ្ជរោ សដ្ឋិហាយនោ
កច្ឆាយ ពជ្ឈមានាយ   កោញ្ចំ នទតិ ភារណោ ។
អាជានិយា ហសិយន្តិ   នេមិឃោសោ អជាយថ
នភំ រជោ អឆាទេសិ   ឧយ្យុត្តា សិរិភាហិនី ។
សា សេនា មហតី អាសិ   ឧយ្យុត្តា ហារិហារិណី
ជាលិនា មគ្គនាយេន   វត្តំ ចាយាសិ បព្វតំ ។
តេ ចារិំសុ ព្រហារញ្ញំ   ពហុសាខំ មហោទកំ

Websites: WatKhemaraRatanaram.org or WatKhmers.org

បុប្ផរុក្ខេហិ សញ្ឆន្នំ ផលរុក្ខេហិ ចូភយំ ។
តត្ថ វិន្ទុស្សរា វគ្គូ នានាវណ្ណា ពហូ ទិជា
កូជន្តមុបកូជន្តិ ឧតុសំបុប្ផិតេ ទុមេ ។
តេ គន្ត្វា ទីឃមទ្ធានំ អហោរត្តានមច្ចយេ
បទេសន្តំ ឧទាគញ្ឆុំ យត្ថ វេស្សន្តរោ អហូតិ ។

សត្តមេ ទិវសេ លុះគំរប់ជា ៧ ថ្ងៃ ជួនស្ដេចនឹងលីលាយាត្រា ឯអស់មន្ត្រីយោធា ក៏ឱ្យត្រួតត្រាតាមកំណត់ សេនារាជរថពាជីកុញ្ជរសឹងរឹករវខ្នាន់ខ្នាប់ សឹងដ៏កាន់នូវកាំភ្លើងធ្នូស្នា រៀបជាជួរជាសង្កាត់ តាមដោយអណ្ដាប់ឆ្វេងស្ដាំ បើនឹងរាប់ជា ១២ អក្ខោភិនី ។ ឯអស់នារីស្នំបរិវារ សឹងដ៏ត្រកាលក្សេមក្សាន្ត ត្បិតនឹងបានមើលព្រឹក្សាព្រៃ ដោយនូវនាសងខាងមាគ៌ា ។ ឯភ្នាក់ងារព្រះសិទ្ធរសក្រចេះចួងច័ន្ទន៍ ព្រះពស្ត្រព្រះស្រីសឹងក្រមុំព្រហ្មចារីយ៍ សមនូវរូបរាង នូវជំទាវនាងខុនណាង ចាស់ទុំក្រមុំសារកែ សឹងដ៏តាមដង្ហែទៅតាមមាគ៌ា សឹងដ៏ប្រដាប់ប្រដាអាត្មាស្រែចស្រស់ស្រឡាបលាបនូវសុគន្ធរស ក្រចេះចួងច័ន្ទសុគន្ធពិដោរ ដើរដោយអណ្ដាប់ នឹងរាប់ជាម៉ឺនជាសែន ទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយនូវផ្លូវ បីដូចកលស្រីនៅនាសួគ៌ាដ៏មានសិរីសួស្ដី ។ លុះព្រឹកព្រាងស្រាងព្រះរស្មីស្រេច ទើបសម្ដេចព្រះបាទស្រីសញ្ជ័យ នូវព្រះអគ្គមហេសី ព្រះរាជនត្តោនត្តា ស្ដេចចូលទៅកក់ស្រង់ នូវព្រះគន្ធរសព្រះពស្ត្រព្រះភូសា ប្រដាប់ប្រដាព្រះកាយាស្រេចហើយ ពុំលង់ឡើយអស់ភ្នាក់ងារ ប្រគំត្រែស័ង្ខរគាំងភេរី តូរ្យតន្ត្រីពិណពាទ្យ ដោយនូវខ្នាតតូចធំ សំឡេងល្វេងល្វើយ ។ ទើបអស់អ្នកភ្លេង ក៏លេងដោយនូវពួកទីទៃ ៗ ស្ដេចមកគង់ឰដ៏ព្រះរាជយានរ័ត្ន ព្រះជាលីគង់គជេន្ទ្រជាមគ្គនាយកនាំក្បួនត្រយាត្រា ឯព្រះអយ្យកាគង់ព្រះរាជយានស្រីសុពណ៌សិវិការស្មីឆាឆាយច្រាលឆ្អៅ ឯអស់យោធាក៏លើកទ័ពចេញទៅគគុកគគឹកឆ្វេងស្ដាំ មុខក្រោយដោយនូវអណ្ដាប់ស័ព្ទកក្រើក រំពើកខ្សៀវខ្វារខ្វ័រខ្វារទាំងពសុធា ដើរដោយនូវជំពូកទីទៃ ៗ ។ ដំរីរាជរថពលរមត់ថ្មើរជើង បើកបរអស្សតរសិន្ធពរាជសឹងដ៏ខ្លោះខ្លាំង ក្រុញ្ជរេ រីឯកុញ្ជរកែវបវរជារាជយានប្រសើរ សិដ្ឋហាយនោ កើតកបលក្ខណា មានអាយុ ៦០ ឆ្នាំសឹងដ៏ត្រេកអររពោទ៍រំពងទ្រហឹងសព្ទចតុរង្គអឺងអាប់ខ្វារខ្វ័រ ។ ឯអស់អម្បាលកំណាន់អស្សតរបើកបរដោយក្បួន ឯខ្លួនឯងនោះសឹងតែ

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រដាប់នូវក្រោះមាស នេមិឃោសោ ពេញពាសតាន់តាប់សំឡេងសូរ សព្ទកង់រាជរថ ឮទ្រហឹងអឹងអាប់ញាប់ញ័រទាំងពសុធា ឯភំរជោ រីផុយផង់ធូលីហើរទៅនាវេហាស៍ ឯអាកាសក៏សឹងដ៏ស្រទំត្រជាក់ ស្រណុកសកលខ្យល់បក់មកត្រសៀក រំភើយផ្សព្វផ្សាយសប្បាយក្សេមក្សាន្តឥតមានទុក្ខសោករោគា ស្តេចលីលាទៅនឹងពល ១២ អក្ខោភិនី ។ ឯថៅជាលីដ៏ជាមគ្គនាយកនាំស្តេចយាត្រា ស្តេចទតសព្វព្រឹក្សាផងទាំងឡាយសប្បាយអភិរមសោមនស្សា គគីរ ឆាំឆា ស្មាក្របី ស្រឡីស្រឡៅ ត្រាច ត្រាត្រៅ ត្រើយ គ្រង់ រង់ ព្រហូត រោករាក់ ក្លាំពាក់ក្លាំពាក្រស្នា ចួងច័ន្ទន៍ សឹងដ៏ដុះតាន់តាប់នៅក្នុងព្រៃ ពហុសាខំ ដ៏មានលំពង់លូតលាស់សាខាផ្លែផ្កា ច្រាសច្រាលរន្ទាលស្រគាលទុំខ្ចី ដោយនៅសងខាងមាគ៌ា ហាក់ដូចជាមានចិត្តទន់ទោរមកថ្វាយ ស្តេចទតសប្បាយក្សេមក្សាន្តព្រះទ័យ ទតអស់បក្សាបក្សីចុះនៅនាព្រៃព្រឹក្សា ទំយំគគឹករកគូជាដើម គឹបហូពូ សេកយា ក្ងានក្ងោក ប៉ោលតោក តាវៅសំឡេងក្រអៅពីរោះល្វេងល្វើយ ដូចកលអ្នកបន្លែងក្នុងព្រៃចាប់ចឹកចំណី ដោយកលបក្សីបក្សា តេ មោះ ចត្តាភេ ខត្តិយា រីឯក្សត្រាក្សត្រី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំង ៤ ព្រះអង្គ ស្ដេចគង់ក្នុងព្រៃជាច្រើនរាត្រី មានព្រះទ័យក្សេមក្សាន្ត សោមនស្សា វេស្សន្តរោ រាជា   រីឯព្រះបាទស្រីវេស្សន្តរបរមពោធិសត្វ ស្ដេចទ្រង់ព្រតនៅនាងណាមិញ ក្សត្រទាំង ៤ ព្រះអង្គ ស្ដេចបរព្រះទីនាំង តំបងេសំ ឆ្ពោះសំដៅទៅប្រទេសនោះឯងហោង ។

មហារាជបព្វំ និដ្ឋិតំ បពិត្រអើយ រីយើងស្រដីសរសើរ ពណ៌នាកណ្ឌមហារាជបព្វ ដ៏ប្រដាប់ប្រដានូវគាថា ៦៩ គាថា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ៚

(ចប់កណ្ឌមហារាជបព្វទី ១១ តែប៉ុណ្ណោះ)

---

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ ភិក្ខុភិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមរឿបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org